# ទិវាឆ្មបជាតិ ២ ឧសភា ឆ្នាំ២០២៤

## ប្រធានបទ៖ ពង្រឹងជំនាញ វិជ្ជាជីវៈឆ្មប ដើម្បីលើកកម្ពស់សេវាថែទាំព្យាបាលសុខភាពមាតា ទារក និងយុវវ័យ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ

# ស្ថានភាពយុវវ័យនៅកម្ពុជា

បង្ហាញដោយលោកស្រី វ៉ែន និត អនុប្រធានកម្មវិធីជាតិសុខភាពបន្តពូជ




**ថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៧**
**សណ្ឋាគារកាំបូឌីយ៉ាណា ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤**

# មាតិការ

១. ស្ថានភាពយុវវ័យ

២. គោលនយោបាយ

៣. ឯកសារសំខាន់ក្រោមកម្មវិធីជាតិសុខភាពបន្តពូជស្តីពីសេវាសុខភាពបន្តពូជ
និងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព

៤. ចំនួនមូលដ្ឋានសុខាភិបាលទទួលបានការបណ្តុះបណ្តាល ២០១៧-២០២៣

៥. ការប្រើប្រាស់សេវាសុខាភិបាលពីសំណាក់យុវវ័យនៅត្រីមាសទី១ឆ្នាំ ២០២១-២០២២-២០២៣

៦. ឧបសគ្គ/បញ្ហាប្រឈមនានា

- កម្ពុជាគឺជាប្រទេសដែលមានប្រជាជនច្រើនជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូច្នេះ ការបង្កើនការផ្តល់ និងការទទួលបានព័ត៌មាន និងសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទប្រកបដោយមិត្តភាព មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ដោះស្រាយបញ្ហានៃការមានផ្ទៃពោះនៅវ័យក្មេង ដែលកំពុងកើតមានឡើង។
- នៅឆ្នាំ២០១០ ដល់២០១៦ កម្ពុជាទទួលបានវឌ្ឍនៈភាពល្អនៅក្នុងការបង្កើនការគ្របដណ្តប់ការអប់រំរឿងផ្លូវភេទគ្រប់ជ្រុងជ្រោយ និងការកើនឡើងនៃចំនួនមណ្ឌលសុខភាពដែលផ្តល់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព។
- ទោះជាយ៉ាងណាក្តីការប្រើប្រាស់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព នៅក្នុងវិស័យសាធារណៈនៅមានតិចតួច។

**យុវវ័យនិងសុខភាពបន្តពូជសុខភាពផ្លូវភេទនៅលើពិភពលោក**

រៀងរាល់ឆ្នាំក្នុងពិភពលោក មានយុវវ័យប្រមាណ១៦លាននាក់ដែលមានអាយុពី ១៥-១៩ ឆ្នាំ បានក្លាយជាម្តាយរបស់គេ។ យុវវ័យដែលមានផ្ទៃពោះនៅវ័យក្មេងភាគច្រើនជាអ្នកក្រីក្រមានការអប់រំតិចតួចហើយរស់នៅក្នុងតំបន់ជនបទ។ ទោះបីជាមានការរីកចំរើន ប៉ុន្តែចំនួនយុវវ័យដែលមានផ្ទៃពោះនៅតែបន្តកើនឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ នៅពេលមានផ្ទៃពោះវ័យក្មេង ជីវិតរបស់នាងមានការផ្លាស់ប្តូរទាំងស្រុង ការសិក្សាអាចនឹងត្រូវបានបញ្ចប់ ហើយអនាគតការងារអាចនឹងបាត់បង់។



- ការពង្រឹងការផ្តល់ព័ត៌មាន និងសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព ត្រូវបានផ្តោតយ៉ាងសំខាន់ក្នុងការអនុវត្តបន្តនៃយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ និងសិទ្ធនៅប្រទេសកម្ពុជា
- កម្មវិធីសិក្សាស្តីពី ការអប់រំរឿងផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) កំពុងដាក់ឱ្យអនុវត្តនៅតាមសាលារៀនមួយចំនួន។



ផលវិបាកជុំវិញការមានផ្ទៃពោះនិងការសម្រាលជាមូលហេតុចំបងនៃមរណភាពមាតានៅក្នុងចំណោមស្ត្រីវ័យក្មេង។ ភាគច្រើនការមានផ្ទៃពោះនៅវ័យក្មេងមិនមែនជាជម្រើស របស់នាងទេ បញ្ហានេះបណ្ដាលមកពីនាងមិនបានទទួលការអប់រំ ទទួលព័ត៌មាននិងសេវាសុខភាព។ ដោយសារយុវវ័យជាច្រើនធាប់ពេញវ័យ បានធ្វើឱ្យពួកគេប្រឈមមុខនឹងការរួមភេទមុនពេលរៀបការ ជាហេតុធ្វើអោយងាយនឹងមានបញ្ហាសុខភាពបន្តពូជ  រួមមានការមានផ្ទៃពោះ ការរំលូតកូនគ្មានសុវត្ថិភាព ការឆ្លងជំងឺកាមរោគ មេរោគអេដស៍ និងការបំពានផ្លូវភេទ។



## តារាងទី2៖ ប្រជាជនជាក្មេងជំទង់និងយុវជនកម្ពុជា នៅចន្លោះឆ្នាំ២០០៨-២០១៩

| ក្រុមអាយុ | បុរស | | ប្រែប្រួល | ស្ត្រី | |
|---|---|---|---|---|---|
| | ២០០៨ | ២០១៩ | (%) | ២០០៨ | ២០១៩ |
| **១០-១៤** | ៨៥៩.៤១២ | ៨៤២.៨៩១ | -២ | ៨១១.០៩៣ | ៨០៤.៩៨៦ |
| **១៥-១៩** | ៨៣៤.៤១៦ | ៧១០.២៣៧ | -១៥ | ៧៨៤.៨៧៤ | ៦៩៩.១១៣ |
| **២០-២៤** | ៦៦៩.៣៤៣ | ៦១១.៣៧៧ | -៩ | ៦៩៩.៨៥៩ | ៦៤៣.៨០៣ |
| **សរុប** | ២.៣៦៣.១៧១ | ២.១៦៤.៥០៥ | - | ២.២៩៥.៨២៦ | ២.១៤៧.៩០២ |

*ប្រភព៖ ជំរឿនប្រជាជនទូទៅ ឆ្នាំ២០០៨ និងជំរឿនប្រជាជនទូទៅ ឆ្នាំ២០១៩*

តារាងទី3៖ ប្រជាជនអាយុចន្លោះពី៦-២៤ឆ្នាំ ដែលបានចូលរៀនតាមក្រុមអាយុជាក់លាក់ និងតាមភេទ នៅចន្លោះឆ្នាំ២០០៨-២០១៩ (គិតជា%)

| ក្រុមអាយុ | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | ស្រី | ប្រុស | ទាំងពីរភេទ | ស្រី | ប្រុស | ទាំងពីរភេទ |
| **៦-១១** | ៧៦,៨ | ៧៦,៩ | ៧៦,៣ | ៩១,១ | ៩០,១ | ៩០,៦ |
| **១២-១៤** | ៨៦,៣ | ៨៧,០ | ៨៦,៧ | ៩២,៨ | ៩០,៤ | ៩១,៦ |
| **១៥-១៧** | ៥៨,៨ | ៦៥,៦ | ៦២,៣ | ៦៩,១ | ៦៦,២ | ៦៧,៦ |
| **១៨-២៤** | ១៦,៥ | ២៦,២ | ២១,៣ | ១៩,៣ | ២២,១ | ២០,៧ |

*ប្រភព៖ ជំរឿនប្រជាជនទូទៅ ឆ្នាំ២០០៨ និងជំរឿនប្រជាជនទូទៅ ឆ្នាំ២០១៩*

## រូបភាពទី2៖ ស្ថានភាពអប់រំរបស់អ្នកឆ្លើយសំណួរដែលបានចូលរួមការស្ទង់មតិ (គិតជា%)




*ចំនួនអ្នកចូលរួម n = ១.០០០នាក់*

# រូបភាពទី10៖ អត្រានៃការសិក្សាតាមកម្រិតសិក្សា ពីឆ្នាំ២០០៩ ដល់ ២០១៩ តាមភេទ (គិតជា%)




| | ២០០៩/១០ | ២០១០/១១ | ២០១១/១២ | ២០១២/១៣ | ២០១៣/១៤ | ២០១៤/១៥ | ២០១៥/១៦ | ២០១៦/១៧ | ២០១៧/១៨ | ២០១៨/១៩ |
|---|---|---|---|---|---|---|---|---|---|---|
| បឋមសិក្សា៖ ប្រុស | ៩៥ | ៩៥,៨ | ៩៦,៧ | ៩៦,៩ | ៩៥,៤ | ៩៤,១ | ៩៣,៣ | ៩៣,២ | ៩២,៤ | ៩២ |
| បឋមសិក្សា៖ ស្រី | ៩៤,៦ | ៩៤,៦ | ៩៦,១ | ៩៧ | ៩៥,៨ | ៩៤,៩ | ៩៤,៧ | ៩៣,៩ | ៩២,៩ | ៩២,៨ |
| មធ្យមសិក្សាបឋមភូមិ៖ ប្រុស | ៥៩ | ៥៩,១ | ៥៥ | ៥៣ | ៥២ | ៥១ | ៥១,១ | ៥២,១ | ៥២,៨ | ៥២,៣ |
| មធ្យមសិក្សាបឋមភូមិ៖ ស្រី | ៥៧,១ | ៥៧,៨ | ៥៥. | ៥៤,២ | ៥៤,៥ | ៥៥,៣ | ៥៦,៧ | ៥៩,៦ | ៦១ | ៦១,១ |
| មធ្យមសិក្សាទុតិយភូមិ៖ ប្រុស | ៣៥,២ | ៣៥,៧ | ៣២,១ | ២៨,៣ | ២៥,២ | ២៣,៨ | ២៣,៣ | ២៣,៦ | ២៤,៧ | ២៥,២ |
| មធ្យមសិក្សាទុតិយភូមិ៖ ស្រី | ២៩,២ | ៣០,១ | ២៨,៩ | ២៦,៤ | ២៤,៦ | ២៤,៦ | ២៤,២ | ២៦,៧ | ២៩,៣ | ៣១,២ |

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា ២០០៩-២០១០ ដល់ ២០១៨-២០១៩*

## រូបភាពទី19៖ និន្នាការនៃអត្រាបោះបង់ការសិក្សាក្នុងការអប់រំចំណេះទូទៅ ពីឆ្នាំ២០០៩ ដល់ ២០១៩ តាមភេទ (គិតជា%)




| | ២០០៩/១០ | ២០១០/១១ | ២០១១/១២ | ២០១២/១៣ | ២០១៣/១៤ | ២០១៤/១៥ | ២០១៥/១៦ | ២០១៦/១៧ | ២០១៧/១៨ | ២០១៨/១៩ |
|---|---|---|---|---|---|---|---|---|---|---|
| បឋមសិក្សា៖ ប្រុស | ៨,៧ | ៨,៨ | ៨,៧ | ២,៨ | ១២,៤ | ៩,៤ | ៧,២ | ៥,៥ | ៤,៧ | ៥,០ |
| បឋមសិក្សា៖ ស្រី | ៧,៩ | ៨,៧ | ៧,៨ | ៤,៧ | ៨,៣ | ៧,២ | ៥,២ | ៣,៨ | ៣,៥ | ៣,៧ |
| មធ្យមសិក្សាបឋមភូមិ៖ ប្រុស | ១៨,២ | ១៩,១ | ២១,៦ | ២១,២ | ២១,៥ | ២១,៧ | ២០,៣ | ១៨,៥ | ១៦,៦ | ១៧,៦ |
| មធ្យមសិក្សាបឋមភូមិ៖ ស្រី | ១៩,៤ | ២០,១ | ២១,៩ | ១៨,៧ | ២០,៩ | ២០,៣ | ១៨,២ | ១៥,៥ | ១៤,២ | ១៤,២ |
| មធ្យមសិក្សាទុតិយភូមិ៖ ប្រុស | ១១,៥ | ១៤,២ | ១៤,២ | ១០,៣ | ១៥,៦ | ២៩,៥ | ២៥,៤ | ២០,៨ | ១៩,៧ | ១៨,២ |
| មធ្យមសិក្សាទុតិយភូមិ៖ ស្រី | ១១,០ | ១៣,១ | ១៣,១ | ៩,៨ | ១២,២ | ២៥,៤ | ២២,២ | ១៧,៩ | ១៧,០ | ១៥,៧ |

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា ២០០៩-២០១០ ដល់ ២០១៨-២០១៩*

## រូបភាពទី21៖ អ្នកធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការបោះបង់ការសិក្សារបស់ក្មេងជំទង់ និងយុវជន (គិតជា%)



## រូបភាពទី42៖  កន្លែងផ្តល់សេវាថែទាំសុខភាពដែលយុវជនបានទៅពិនិត្យភាពស្លេកស្លាំង (គិតជា%)




*ចំនួនអ្នកចូលរួមបានឆ្លើយសំណួរដែលបានធ្វើតេស្តរកភាពស្លេកស្លាំង n = ៥៧នាក់*

រូបភាពទី44៖ ក្មេងជំទង់ និងយុវជនដែលបានពិនិត្យសុខភាពជាទៀងទាត់ (គិតជា%)



## រូបភាពទី50៖ ទីកន្លែងដែលអ្នកឆ្លើយសំណួរចូលចិត្តទៅទទួលសេវាថែទាំសុខភាព តាមភេទ (គិតជា%)




*ចំនួនអ្នកចូលរួម n= ១.០០០នាក់*

**សេវាសុខភាពយុវវ័យប្រកបដោយមិត្តភាព** : មានន័យថាសេវាដែលបានផ្តល់ដោយបុគ្គលិកសុខាភិបាលដែលមានជំនាញនិងសមត្ថភាព ក្នុងគោលបំណងការពារបញ្ហាសុខភាព ធ្វើរោគវិនិច្ឆ័យនិងព្យាបាល។ សេវាទាំងនេះរួមបញ្ចូលទាំងការផ្តល់ព័ត៌មាន ដំបូន្មាននិងការផ្តល់ប្រឹក្សា ដោយធានារក្សាការសម្ងាត់ យកចិត្តទុកដាក់ដល់យុវវ័យមានសម្ភារ និងឱសថគ្រប់គ្រាន់ មានប្រព័ន្ធបញ្ជូន តម្លៃសេវាសមស្រប មានទីកន្លែង ពេលវេលាដោយឡែកសម្រាប់យុវវ័យ និងមិនរង់ចាំយូរ។



## បញ្ហាចម្បងៗដែលប៉ះពាល់ដល់សុខភាពយុវវ័យនៅកម្ពុជាមានដូចជា៖

- គ្រោះថ្នាក់នានា អំពើហិង្សា ការប៉ុនប៉ងធ្វើអត្តឃាត
- បញ្ហាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ
- ការមានផ្ទៃពោះនៅវ័យក្មេង
- ជំងឺកាមរោគ/មេរោគអេដស៍
- ការប្រើសារធាតុញៀន (បារី ស្រា និងគ្រឿងញៀនផ្សេងៗ)
- បញ្ហាសុខភាពផ្លូវចិត្ត
- បញ្ហាអាហារូបត្ថម្ភ។

- ការពពោះវ័យជំទង់ជាបញ្ហាសុខភាពដ៏សំខាន់ទាក់ទងនឹងជំងឺ និងអត្រាមរណៈភាពខ្ពស់សម្រាប់ម្តាយ និងទារក។ ការបង្កើតកូនវ័យជំទង់ អាចរងឥទ្ធិពលអាក្រក់ក្នុងសង្គម ជាពិសេសការទទួលបានការអប់រំ ដោយសារស្ត្រីដែលក្លាយជាម្តាយក្នុងវ័យជំទង់អាចបោះបង់ចោលការសិក្សា។ នៅកម្ពុជាស្ត្រី ៩% មានអាយុ ១៥ - ១៩ឆ្នាំ បានចាប់ផ្តើមពពោះ។
- ប្រមាណ២%នៃស្ត្រី អាយុ១៥ - ១៩ឆ្នាំ បានរៀបការនៅអាយុ១៥ឆ្នាំ ហើយតិចជាង១% ធ្លាប់សម្រាលកូន ឬធ្លាប់ពពោះ។ គ្មានបុរសណាម្នាក់បានរាយការណ៍ថា បានរៀបការ ឬបង្កើតកូនមុនអាយុ១៥ឆ្នាំឡើយ។ (CDHS 21-22)

## ទម្រង់ការពរពោះវ័យជំទង់តាមចរិតលក្ខណៈអង្កេត

- ភាគរយស្ត្រីអាយុ ១៥-១៩ ឆ្នាំធ្លាប់ពរពោះកើនឡើងតាមអាយុពី ១% ក្នុងចំណោមស្ត្រីអាយុ ១៥ ទៅ ៣០% ក្នុងចំណោមស្ត្រីអាយុ ១៩ ឆ្នាំ។
- ការមានពរពោះក្នុងវ័យជំទង់មានខ្ពស់នៅជនបទជាងទីប្រជុំជន (១០% ធៀបនឹង ៨%) (តារាង ៥.១២)។
- តាមរាជធានី ខេត្ត ភាគរយស្ត្រីវ័យជំទង់ដែលចាប់ផ្តើមបង្កើតកូនមានខ្ពស់បំផុតនៅខេត្តស្ទឹងត្រែង (២៥%) និងទាបបំផុតនៅខេត្តកណ្តាល (៤%)

**ផែនទី ៥.២ ការពរពោះក្នុងវ័យជំទង់តាមរាជធានី ខេត្ត**

ភាគរយស្ត្រីអាយុ ១៥-១៩ ឆ្នាំធ្លាប់ពរពោះ



- ការពរពោះវ័យជំទង់មិនសូវកើតមានសម្រាប់គ្រួសារដែលមានសន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុតនោះទេ មានតែ ៤% នៃស្ត្រីដែលមានសន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិខ្ពស់បំផុតចាប់ផ្តើមបង្កើតកូនធៀបនឹង ១៦% នៃស្ត្រី ដែលមានសន្ទស្សន៍បញ្ចភាគទ្រព្យសម្បត្តិទាបបំផុត (តារាង ៥.១២)។



## ➢ តួនាទីនិងភារកិច្ចរបស់អ្នកផ្តល់សេវាសុខភាព

១. កំណត់បញ្ហា

២. ផ្តល់ព័ត៌មាននិងជំរើសដល់យុវវ័យ

៣. ជួយយុវវ័យក្នុងការសម្រេចចិត្ត

៤. ផ្តល់សេវា



## ➢ សេវាសុខភាពដែលយុវវ័យត្រូវទទួលបាន

- អនាម័យនិងការថែទាំសុខភាពបឋម
- ការពិគ្រោះពិភក្សាមុនរៀបអាពាហ៍ពិពាហ៍
- ការពន្យារកំណើត
- ការពិគ្រោះពិភាក្សាអំពីមេរោគអេដស៍
- ការថែទាំផ្ទៃពោះ ថែទាំពេលសម្រាលនិងក្រោយសម្រាល
- ការពិគ្រោះពិភាក្សាពីយេនឌ័រ , ក្រោយទទួលរងអំពើហិង្សាផ្លូវភេទនិងការរំលោភបំពាន
- ការពិគ្រោះពិភាក្សាមុននិងក្រោយពេលរំលូត។

# ឧបសគ្គចំពោះការប្រើសេវា

## ១. ឧបសគ្គរបស់យុវវ័យ

ឧបសគ្គដែលយុវវ័យប្រឈមនឹងការទទួលបាននូវសេវាសុខភាព៖

- តម្លៃសេវា
- ថ្លៃធ្វើដំណើរ
- ម៉ោងធ្វើការ
- ខ្មាសអៀន ឬមិនហ៊ានរកជំនួយពេលមានបញ្ហាសុខភាពផ្លូវភេទ ឬសុខភាពផ្លូវចិត្ត
- ភ័យខ្លាចការមិនរក្សាព័ត៌មានសម្ងាត់ ឬគ្មានឯកជនភាព និងខ្លាចជួបនរណាម្នាក់ដែលស្គាល់
- មិនយល់អំពីតម្រូវការថែទាំសុខភាពផ្ទាល់របស់ពួកគេ
- មិនដឹងអំពីសេវាដែលផ្តល់ឱ្យ
- មិនដឹងអំពីរបៀបប្រើសេវា កន្លែងដែលត្រូវទៅនិងទៅដល់ទីនោះ  ដោយរបៀបណា
- ព្រួយបារម្ភពេលអ្នកផ្តល់សេវាសម្រេចចិត្តឬបង្គាប់ឱ្យធ្វើអ្វីមួយ
- ចម្ងាយផ្លូវទៅគ្លីនិក
- មិនចង់ទៅម្នាក់ឯងនិងមិនមាននរណាទៅជាមួយ
- បរិយាកាសនៅគ្លីនិកមានភាពភ័យខ្លាច។

# ឧបសគ្គចំពោះការប្រើសេវា

## ២. *ឧបសគ្គរបស់អ្នកផ្តល់សេវា*

ឧបសគ្គដែលអ្នកផ្តល់សេវាជួបប្រទះមានដូចខាងក្រោម៖

- មិនបានទទួលការបណ្តុះបណ្តាលការផ្តល់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទយុវវ័យ
- ខ្វះទំនុកចិត្ត ចំណេះដឹង និងជំនាញក្នុងការទំនាក់ទំនងជាមួយយុវវ័យ
- មិនមានកន្លែងផ្តល់សេវាដាច់ដោយឡែកសម្រាប់យុវវ័យ
- ពេលវេលាមានកម្រិតក្នុងការផ្តល់សេវា។

# គោលនយោបាយ

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ទៅលើផ្នែកសុខភាព ជាចំបងដែលក្នុងនោះ មានសុខភាពបន្ត ពូជយុវវ័យផងដែរ។ មានគោលនយោបាយ ជាច្រើនបានគាំទ្រដល់ ការសុខភាពបន្តពូជ និងសុខភាពយុវវ័យ

- គោលនយោបាយជាតិស្តីពីការពន្យារកំណើត ១៩៩៥
- ច្បាប់រំលូតកូន ១៩៩៧
- គោលនយោបាយនិងយុទ្ធសាស្ត្រជាតិស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ ១៩៩៧
- គោលនយោបាយជាតិស្តីពីការការពារការឆ្លងរោគពីម្តាយទៅកូន ២០០១
- ប្រកាសស្តីពីការណែនាំអនុវត្តច្បាប់រំលូតកូន ២០០២
- គោលនយោបាយអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្តនិងផ្តល់ប្រឹក្សាដោយរក្សាការសម្ងាត់ ២០០២
- គោលដៅអភិវឌ្ឍន៍សហសវត្ស ២០០៥-២០១៥
- គោលការណ៍ណែនាំសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ របស់យុវវ័យ ២០០៨
- ផែនការយុទ្ធសាស្ត្រជាតិសម្រាប់វិស័យសុខាភិបាល ២០០៨-២០១៥
- ផែនការយុទ្ធសាស្ត្រជាតិពហុវិស័យសម្រាប់ការឆ្លើយតបទៅនឹង មេរោគអេដស៍/ជំងឺអេដស៍ ២០១១-២០១៥
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ២០១១
- គោលនយោបាយនិងគោលការណ៍ណែនាំជាតិសម្រាប់ ការផ្តល់បន្ថែមមីក្រូសារជាតិដើម្បីការពារនិងទប់ស្កាត់បញ្ហា កង្វះមីក្រូសារជាតិនៅប្រទេសកម្ពុជា ២០១២
- ផែនការយុទ្ធសាស្ត្រជាតិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ២០១៣-២០១៦
- គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០
- ផែនទីចង្អុលផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក ២០១៦-២០២០

# គោលនយោបាយ (ឥ)

ដើម្បីលើកកម្ពស់ សុខភាពបន្តពូជ និងសុខភាពយុវវ័យ ជាពិសេសសម្រាប់កាត់បន្ថយការមានផ្ទៃពោះក្នុងចំណោមស្ត្រីវ័យក្មេងអាយុក្រោម២០ឆ្នាំ កម្មវិធីជាតិសុខភាពបន្តពូជ នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកបានបញ្ចូលការផ្តល់ព័ត៌មាន និងសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាពទៅក្នុងផែនការយុទ្ធសាស្ត្ររបស់កម្មវិធីឆ្នាំ២០១៧-២០២៣ (កំពុងធ្វើបច្ចុប្បន្នភាព ២០២៤ - ២០៣០)។

# ឯកសារសំខាន់ក្រោមកម្មវិធីជាតិសុខភាពបន្តពូជ
# ស្តីពីសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព






# ឯកសារសំខាន់ក្រោមកម្មវិធីជាតិសុខភាពបន្តពូជ
# ស្តីពីសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាព



# ការគាំទ្រនៅមូលដ្ឋាន



# ដៃគូអភិវឌ្ឍន៍ដែលគាំទ្រការអនុវត្តសកម្មភាពសុខភាពបន្តពូជយុវវ័យមាន ៖

- UNFPA
- MSIC
- RHAC
- Plan International Cambodia
- HACC
- CHEZ…

# ចំនួនយុវវ័យទទួលសេវាសុខភាពនៅតាមមូលដ្ឋានសុខាភិបាល ត្រីមាសទី១ ឆ្នាំ ២០២១-២០២២-២០២៣ ទាំង៨ខេត្ត



# ចំនួនយុវជនទទួលសេវាសុខភាពនៅតាមមូលដ្ឋានសុខាភិបាលទាំង ៨ ខេត្តក្នុងឆ្នាំ២០២៣



# ឧបសគ្គ-បញ្ហាប្រឈម

- យុវវ័យមួយចំនួនបានបោះបង់ការសិក្សា និងបានរៀបការវ័យក្មេង ហើយពួកគេភាគច្រើនមិនបានមកប្រឹក្សាមុនពេលរៀបការ
- ចំនួនមូលដ្ឋានសុខាភិបាលទទួលបានការបណ្តុះបណ្តាលអំពីសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទយុវវ័យប្រកបដោយមិត្តភាពមានចំនួនតិចធៀបទៅនឹងមូលដ្ឋានសុខាភិបាល នៅទូទាំងខេត្ត
- ថវិកាមានតិចតួចសម្រាប់ចុះអភិបាលការផ្តល់សេវាពីថ្នាក់ជាតិទៅថ្នាក់ខេត្ត និងពីខេត្តទៅ មូលដ្ឋានសុខាភិបាល
- ថវិកាសម្រាប់ផ្សព្វផ្សាយសេវានៅសហគមន៍មានចំនួនតិតតួច

# ឧបសគ្គ-បញ្ហាប្រឈម (បន្ត)

- ការផ្តល់ការពិគ្រោះពិភាក្សាជាមួយយុវវ័យនៅមានកម្រិត
- នៅតាមមូលដ្ឋានសុខាភិបាលភាគច្រើនមិនមានបន្ទប់ដាច់ដោយឡែក សម្រាប់ផ្តល់សេវាដល់យុវវ័យ
- មិនមានថវិកាក្នុងការចុះអប់រំផ្សព្វផ្សាយ តាមសាលារៀន សហគមន៍...។

# ទិសដៅបន្ត ៖

- ពង្រីកវិសាលភាពនៃការផ្តល់សេវាសុខភាពបន្តពូជ សុខភាពផ្លូវភេទយុវវ័យតាមរយៈ ៖
  - បន្តការគាំទ្រសេវា នៅក្នុងយុទ្ធសាស្ត្រជាតិសុខភាពបន្តពូជ សុខភាពផ្លូវភេទ
  - ការបង្កើនបណ្តុះបណ្តាលដល់អ្នកផ្តល់សេវា នៅតាមមូលដ្ឋានសុខាភិបាល
  - ពង្រឹងជំនាញអ្នកផ្តល់សេវាតាមរយៈការពិនិត្យតាមដាន ឬការបង្វឹក
  - ពង្រីកការផ្សព្វផ្សាយពីការអាចទទួលបានសេវាសុខភាពបន្តពូជ សុខភាពផ្លូវភេទយុវវ័យ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។



Thank You


International
day of the
midwife